# អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១

## ផ្នែកទី៥៖ កម្លាំងពលកម្ម និងសកម្មភាពសេដ្ឋកិច្ច



# កម្លាំងពលកម្ម សកម្មភាពសេដ្ឋកិច្ច គ្រោះហានិភ័យ និងប្រាក់កម្ចី

អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១ គ្របដណ្ដប់ការឆ្លាស់គ្នានៃម៉ូឌុល (Module) ហើយបានរួមបញ្ចូលសំណួរពាក់ព័ន្ធនឹងសូចនាកររងសេដ្ឋកិច្ច ដើម្បីឆ្លើយតបគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ២.៤.១ ។ ម៉ូឌុលនេះ បានរួមបញ្ចូលសំណួរជាច្រើនទាក់ទងនឹងការចំណូលចំណាយនៃកសិដ្ឋាន។ លើសពីនេះ របាយការណ៍ក៏បានបញ្ចូលផងដែរ នូវលទ្ធផលដែលពាក់ព័ន្ធនឹងកម្លាំងពលកម្ម គ្រោះហានិភ័យ និងប្រាក់កម្ចី ដែលជះឥទ្ធិពលលើសេដ្ឋកិច្ចគ្រួសារកសិកម្ម។



## កម្លាំងពលកម្ម

នៅតំបន់វាលទំនាប សមាជិកគ្រួសារកសិកម្មបានចូលរួមចំណែកធ្វើការងារកសិកម្មច្រើនជាងគេ មានភេទប្រុសចំនួនប្រមាណ ១,២លាននាក់ និងភេទស្រីចំនួនប្រមាណ ១,២លាននាក់ បន្ទាប់មកនៅតំបន់បឹងទន្លេសាប ហើយតំបន់ភ្នំ និងខ្ពង់រាប និងនៅតំបន់ឆ្នេរសមុទ្រមានសមាជិកគ្រួសារតិចជាងគេដែលធ្វើការងារកសិកម្មក្នុងកសិដ្ឋាន។ សមាជិកគ្រួសារកសិកម្មភេទស្រី និងភេទប្រុស គឺមានសមាមាត្រប្រហាក់ប្រហែលគ្នានៅក្នុងតំបន់នីមួយៗ។ សម្រាប់តំបន់បឹងទន្លេសាប មានភាពខុសគ្នាខ្លះ សមាជិកគ្រួសារជាភេទប្រុសមានប្រមាណ ៥១% និងសមាជិកគ្រួសារជាភេទស្រីមានប្រមាណ ៤៩% ដែលបានចូលរួមធ្វើការងារក្នុងកសិដ្ឋាន។

រូបទី ៥.១ ចំនួនសមាជិកគ្រួសារធ្វើការងារក្នុងកសិដ្ឋាន តាមភេទ និងតាមតំបន់ ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១*

រូបទី៥.២៖ បង្ហាញចំនួនម៉ោងធ្វើការងារជាមធ្យមរបស់សមាជិកគ្រួសារភេទស្រី និងភេទប្រុសក្នុងកសិដ្ឋាន។ ទិន្នន័យបានបង្ហាញថាភេទប្រុសបានចំណាយម៉ោងធ្វើការងារក្នុងកសិដ្ឋានច្រើនជាងភេទស្រី គ្រប់តំបន់ទាំងបួននៃប្រទេសកម្ពុជា។ ចំពោះនៅតំបន់ភ្នំ និងខ្ពង់រាបមាជិកគ្រួសារជាភេទប្រុសបានចំណាយម៉ោងធ្វើការងារជាមធ្យមប្រមាណ ៩០៧ ម៉ោងបើប្រៀបធៀបទៅនិងសមាជិកគ្រួសារជាភេទស្រីបានចំណាយម៉ោងធ្វើការងារជាមធ្យមប្រមាណ ៦៩០ ម៉ោងក្នុងកសិដ្ឋាន។ ដូចគ្នានេះដែរ ទិន្នន័យបានបង្ហាញថា នៅតំបន់បឹងទន្លេសាប តំបន់វាលទំនាប និងតំបន់ឆ្នេរសមុទ្រមានជាលំដាប់លំដោយរៀងគ្នា។

រូបទី៥.២ ចំនួនម៉ោងធ្វើការជាមធ្យមលើកសិដ្ឋានក្នុង១ឆ្នាំ តាមភេទ តំបន់ ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១*

ការដាំដុះដំណាំ គឺជាប្រភេទសកម្មភាពកសិកម្ម ដែលគ្រួសារកាន់កាប់កសិកម្មបានចំណាយពេលធ្វើការងារច្រើនជាងគេបំផុត។ គ្រួសារកាន់កាប់កសិកម្មបានចំណាយពេលធ្វើការងារលើការដាំដុះដំណាំសរុបមានប្រមាណ ៦៦%។ សកម្មភាពរបស់គ្រួសារកាន់កាប់កសិកម្មបានចំណាយពេលធ្វើការងារធំទីពីរគឺ

ការចិញ្ចឹមបសុសត្វ ឬបសុបក្សី ដែលមានប្រមាណ ៤៩,៧%។ គ្រួសារកាន់កាប់កសិកម្មបានចំណាយពេលធ្វើការងារលើវារីវប្បកម្ម ឬសកម្មភាពនេសាទមានប្រមាណ ២៦,៦% និងសកម្មភាពប្រមូលអុស ឈើ ឬផលិតផលពីព្រៃ មានប្រមាណ ១៨,៦%។

រូបទី៥.៣ ភាគរយនៃពេលវេលាបានចំណាយលើសកម្មភាពនីមួយៗ នៅកម្ពុជា ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

រូបទី៥.៤៖ បានបង្ហាញអំពីចំនួនកសិដ្ឋានដែលជួលកម្មករពីខាងក្រៅ តាមតំបន់ផ្សេងៗគ្នា។ ទិន្នន័យបានបង្ហាញថានៅតំបន់ភ្នំ និងខ្ពង់រាប បានជួលកម្មករពីខាងក្រៅមានចំនួនខ្ពស់ជាងគេ គឺប្រមាណ ១៣.០០០ បន្ទាប់គឺតំបន់វាលទំនាប ប្រមាណ ១០.០០០ និងតំបន់បឹងទន្លេសាបប្រហែល ៦.០០០ ដែលមានគ្រួសារកាន់កាប់កសិកម្មបានជួលកម្មករពីខាងក្រៅ។ ទោះជាយ៉ាងណានៅតំបន់ឆ្នេរសមុទ្រ មិនមានការបង្ហាញអំពីទិន្នន័យលម្អិតទេ ដោយសារការឆ្លើយតបមិនបានឲ្យគៀកនឹងស្ថិតិលម្អិត។

រូបភាពទី៥.៤ ចំនួនកសិដ្ឋានបានជួលកម្មករពីខាងក្រៅ តាមតំបន់ ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១*

រូបភាពទី៥.៥៖ បានបង្ហាញអំពីចំនួនសរុបនៃកម្មករជួលពីខាងក្រៅធ្វើការពេញម៉ោង តាមភេទ។ លទ្ធផលបានបង្ហាញថា ចំនួនអ្នកធ្វើការងារកសិកម្មជាភេទប្រុសមានប្រមាណ ៦៨.០០០ គឺខ្ពស់ជាងចំនួនអ្នកធ្វើការងារកសិកម្មជាភេទស្រីមានប្រមាណ ៤៦.០០០ នៅទូទាំងប្រទេស។

រូបទី៥.៥ ចំនួនកម្មករសរុបជួលពីខាងក្រៅ ធ្វើការពេញម៉ោង តាមភេទ នៅកម្ពុជា ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

រូបទី៥.៦៖ បង្ហាញចំនួនគ្រួសារកសិកម្មមានជួលកម្មករធ្វើការម្តងម្កាលតាមតំបន់។ ចំនួននៃកសិដ្ឋានមានជួលកម្មករធ្វើការម្តងម្កាល គឺខ្ពស់ជាងកម្មករជួលពីខាងក្រៅ (រូបទី៥.៤ ខាងលើ) ។ តំបន់បឹងទន្លេសាបមានចំនួនខ្ពស់ជាងគេគឺមានចំនួនប្រមាណ ២០៤.០០០ កសិដ្ឋានដែលជួលកម្មករធ្វើការម្តងម្កាល។ តំបន់វាលទំនាបមានប្រមាណ ១៧២.០០០ កសិដ្ឋានតំបន់ភ្នំនិងខ្ពង់រាបមានប្រមាណ ៦៩.០០០ កសិដ្ឋាន និងតំបន់ឆ្នេរសមុទ្រមានប្រមាណ ១៩.០០០ កសិដ្ឋាន។

រូបភាពទី៥.៦ ចំនួនកសិដ្ឋានមានជួលកម្មករធ្វើការម្តងម្កាល តាមតំបន់ នៅកម្ពុជា ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

រូបទី៥.៧៖ បានបង្ហាញចំនួនកម្មករធ្វើការម្តងម្កាលតាមភេទ។ នៅតំបន់បឹងទន្លេសាប និងតំបន់វាលទំនាប ទាំងពីរតំបន់ បង្ហាញចំនួនកម្មករធ្វើការម្តងម្កាលភេទប្រុសច្រើនជាងចំនួនកម្មករធ្វើការម្តងម្កាលដែលជាភេទស្រី។ តែទោះជាយ៉ាងណាក៏ដោយ នៅតំបន់ភ្នំ និងខ្ពង់រាប បានបង្ហាញថា ចំនួនកម្មករជាភេទស្រីធ្វើការម្តងម្កាល មានប្រមាណ ៤១៨.០០០ ខ្ពស់ជាងកម្មករធ្វើការម្តងម្កាលដែលជាភេទប្រុសមានប្រមាណ ២៤៧.០០០។

រូបទី៥.៧ ចំនួនកម្មករធ្វើការម្តងម្កាល តាមភេទ តំបន់ ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

កសិដ្ឋាននៅតំបន់វាលទំនាបបានរាយការណ៍ថា ការចំណាយប្រាក់ឈ្នួលលើកម្មករធ្វើការម្តងម្កាល មានចំនួនខ្ពស់ជាងគេ គឺប្រមាណ១៣,៦ដុល្លារ ក្នុង១ថ្ងៃ។ ចំពោះនៅតំបន់ទាំងពីរ គឺតំបន់បឹងទន្លេសាប និងតំបន់ឆ្នេរសមុទ្រ ក៏បានបង្ហាញដែរថា ការចំណាយទៅលើកម្មករធ្វើការម្តងម្កាលជាមធ្យមប្រមាណ ១១,១ដុល្លារ ក្នុង១ថ្ងៃ ។ ម្យ៉ាងវិញទៀតចំណែកនៅតំបន់ភ្នំ និងខ្ពង់រាបក៏បានរាយការណ៍ថា ប្រាក់ឈ្នួលជាមធ្យមរបស់កម្មករធ្វើការម្តងម្កាលមានការថយចុះជាលំដាប់ប្រមាណ ៧,៦ដុល្លារ ក្នុង១ថ្ងៃ។

រូបទី៥.៨ ប្រាក់ឈ្នួលជាមធ្យមក្នុង១ថ្ងៃសម្រាប់កម្មករធ្វើការម្តងម្កាល តាមតំបន់ ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១*

រូបទី៥.៩៖ បង្ហាញអំពីប្រាក់ឈ្នួលប្រចាំខែជាមធ្យមសម្រាប់កម្មករជួលពីខាងក្រៅនៅតាមតំបន់។ កម្មករជួលពីខាងក្រៅនៅតំបន់ឆ្នេរសមុទ្រ មានប្រាក់ឈ្នួលប្រចាំខែជាមធ្យមខ្ពស់ជាងគេប្រមាណ ២៣០ដុល្លារក្នុង១ខែ។ ចំណែកនៅតំបន់ទាំងបីផ្សេងទៀតបានរាយការណ៍ថា ប្រាក់ឈ្នួលប្រចាំខែជាមធ្យមសម្រាប់កម្មករជួលពីខាងក្រៅមានប្រហាក់ប្រហែលគ្នាចំនួនប្រមាណ ១៥០ដុល្លារ ក្នុង១ខែ សម្រាប់នៅតំបន់វាលទំនាប និងសម្រាប់នៅតំបន់ទាំងពីរ គឺតំបន់បឹងទន្លេសាប និងតំបន់ភ្នំនិងខ្ពង់រាប ប្រាក់ឈ្នួលប្រចាំខែជាមធ្យមសម្រាប់កម្មករជួលពីខាងក្រៅមានប្រមាណ ១៤០ដុល្លារ ។

រូបទី៥.៩ ប្រាក់ខែជាមធ្យមសម្រាប់កម្មករជួលពីខាងក្រៅធ្វើការពេញម៉ោង តាមតំបន់ ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

## សកម្មភាពសេដ្ឋកិច្ច



គ្រួសារកាន់កាប់កសិកម្មភាគច្រើនមានប្រមាណ ២,១៨៣លាន នៃគ្រួសារសរុបប្រមាណ ២,២២៦ លាន ជាម្ចាស់កម្មសិទ្ធិដីធ្លីដែលមានសកម្មភាពកសិកម្ម។ ការជួលដីកសិកម្មដែលប្រើប្រាស់ភាគច្រើនជួលរយៈពេលខ្លី (តិចជាង៣ឆ្នាំ) មានកិច្ចព្រមព្រៀងប្រៀបធៀបទៅនឹងជួលរយៈពេលវែង (៣ឆ្នាំ ឬច្រើនជាង) មានកិច្ចព្រមព្រៀង។

រូបទី៥.១០ ចំនួនគ្រួសារកសិកម្មមានកិច្ចសន្យាជួលក្នុងរយៈពេលខ្លី និងរយៈពេលវែង ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

ទិន្នន័យបានរាយការណ៍ពីការអង្កេតកសិកម្មកម្ពុជា បង្ហាញថា តម្លៃដីមានការកើនឡើងគ្រប់ពេលវេលាពី ២.៦០០ដុល្លារ ក្នុង១ហិកតានៅមុនឬក្នុងឆ្នាំ២០០០ ទៅដល់ ៧.៥០០ដុល្លារ ក្នុង១ហិកតាសម្រាប់ការទិញក្នុងឆ្នាំ២០២១។

**រូបទី៥.១១ តម្លៃដីនៃកសិដ្ឋានជាមធ្យមក្នុង១ហិកតា តាមឆ្នាំបានទិញ នៅកម្ពុជា ឆ្នាំ២០២១**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

រូបទី៥.១២៖ បង្ហាញពីការចំណាយដែលកើតឡើង ដោយកសិដ្ឋានសម្រាប់ធ្វើសកម្មភាពកសិកម្មពេញមួយឆ្នាំ។ មុខចំណាយដែលកសិដ្ឋានបានចំណាយច្រើនបំផុតគឺ "ការចំណាយផ្សេងទៀត" ប្រមាណ ២៨២,៩ដុល្លារ ក្នុង១ឆ្នាំ ។ បន្ទាប់មក គឺការចំណាយកម្លាំងពលកម្មក្រោយប្រមូលផលមានប្រមាណ ២៤២,៥ដុល្លារ ការជួលអគារកសិដ្ឋាន ២១៩,៥ដុល្លារ និងការជួលគ្រឿងចក្រ ឧបករណ៍ ឬមធ្យាបាយដឹកជញ្ជូន ១៩៧,៣ដុល្លារ គឺជាការចំណាយខ្ពស់បន្ទាប់។

**រូបទី៥.១២ ការចំណាយផ្សេងទៀតដែលកើតឡើងដោយកសិដ្ឋាន តាមប្រភេទការចំណាយនៅកម្ពុជា ឆ្នាំ២០២១**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

ការធ្វើវារីវប្បកម្ម និងនេសាទ បានផ្តល់បរិមាណផលកសិកម្មជាតម្លៃច្រើនជាងគេប្រមាណ ១.៦៤៣ លានដុល្លារ ដំណាំមានតម្លៃប្រមាណ ១.១៦៩លានដុល្លារ បសុសត្វផលិតផលសត្វមានប្រមាណ ១៧៧ លានដុល្លារ និងផលព្រៃឈើ មានត្រឹមតែ ៨២លានដុល្លារ។

រូបទី៥.១៣ បរិមាណផលកសិកម្មជាតម្លៃតាមប្រភេទ នៅកម្ពុជា ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

រូបទី៥.១៤៖ បង្ហាញថាគ្រួសារកាន់កាប់កសិកម្មមានប្រមាណ ៨៣២.០០០ ធ្វើកសិកម្មជាចម្បងសម្រាប់លក់ និងគ្រួសារកាន់កាប់កសិកម្មប្រមាណ ៧០២.០០០ សម្រាប់ប្រើប្រាស់ក្នុងគ្រួសារ។ ដោយឡែកគ្រួសារកាន់កាប់កសិកម្មចំនួនប្រមាណ ៥៨៤.០០០ ធ្វើកសិកម្មជាចម្បងសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ និងគ្រួសារកសិកម្មប្រមាណ ១០៩.០០០ ផលិតទិន្នផលដើម្បីលក់តែប៉ុណ្ណោះ។

រូបទី៥.១៤ កសិដ្ឋាន តាមគោលបំណងចម្បងនៃផលិតកម្មកសិកម្ម នៅកម្ពុជា ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

ចំនួនគ្រួសារកាន់កាប់កសិកម្មប្រមាណ ៧៨១.០០០ បានរាយការណ៍ថា ប្រហែលពាក់កណ្តាលនៃគ្រួសារកាន់កាប់កសិកម្មទាំងនោះ មានចំណូលមកពីសកម្មភាពកសិកម្ម ៤០ - ៥៩%។ មានតែគ្រួសារកសិកម្មប្រមាណ ៩១.០០០ បានរាយការណ៍ថា មានចំណូលសរុប ពឹងផ្អែកតែលើទិន្នផលកសិកម្ម។ គ្រួសារកសិកម្មជាច្រើនប្រហែលបីដងគឺ ២៩៥.០០០ បានរាយការណ៍ថា ប្រាក់ចំណូលរបស់គ្រួសារបានមកពីសកម្មភាពកសិកម្ម មានតិចជាងប្រមាណ ១០%។

រូបទី៥.១៥ ប្រាក់ចំណូលពីកសិកម្មរួមចំណែកដល់ប្រាក់ចំណូលសរុបរបស់គ្រួសារ នៅកម្ពុជា ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

ផែនទី ៨.១៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាចំណូលពីកសិកម្មរួមចំណែក ៦០%-១០០% នៃចំណូលសរុបរបស់គ្រួសារ គិតជាភាគរយ បែងចែកតាមខេត្ត៖ ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១ ការជ្រើសរើសនៅលើផែនទី NIS-MOP, MAFF ឆ្នាំ២០២៣*

ចាប់តាំងពីឆ្នាំ២០១៩ គ្រួសារកាន់កាប់កសិកម្ម បានរកឃើញថា កាន់តែពិបាកក្នុងការរកប្រាក់ចំណេញ។ ចំនួនគ្រួសារកសិកម្មបានរបាយការណ៍ផ្ទាល់ពីប្រាក់ចំណេញរវាងឆ្នាំ២០១៩ និង ឆ្នាំ២០២១ មានការថយចុះពីមួយឆ្នាំទៅមួយឆ្នាំប្រមាណ ១.៣៧៧.០០០ គ្រួសារកសិកម្មក្នុងឆ្នាំ ២០១៨-២០១៩ គ្រួសារកសិកម្មមានប្រមាណ ១.២១៣.០០០ ក្នុងឆ្នាំ២០១៩-២០២០ និងប្រហែល ១.០៨១.០០០ ក្នុងឆ្នាំ ២០២០-២០២១។ ដោយមានការជួបគ្រោះហានិភ័យពីជំងឺកូវីដ-១៩ គឺជាកត្តាសំខាន់ក្នុងការលំបាកទាំងនេះ ជាពិសេសដោយសារកម្ពុជាមានអារម្មណ៍ភ័យខ្លាចពីជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០២១។

រូបទី៥.១៦ ចំនួនកសិដ្ឋានដែលបានរាយការណ៍ផ្ទាល់ ទទួលបានផលប្រយោជន៍ក្នុងឆ្នាំយោងនីមួយៗ នៅកម្ពុជា ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

រូបទី៥.១៧ និង រូបទី៥.១៨៖ បានបង្ហាញពីការចូលរួមរបស់គ្រួសារកាន់កាប់កសិកម្ម នៅក្នុងសមាគមកសិករក្រៅផ្លូវការ និងផ្លូវការ (បានចុះបញ្ជីជាមួយរដ្ឋាភិបាល)។ ទាំងសមាគមកសិករផ្លូវការ និងក្រៅផ្លូវការ គឺមានចំនួនធំជាងគេនៅក្នុងតំបន់វាលទំនាប។

រូបទី៥.១៧ ការចូលរួមនៅក្នុងសមាគមកសិករក្រៅផ្លូវការ តាមតំបន់ ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

រូបទី៥.១៨ ការចូលរួមក្នុងសហគមន៍កសិកម្មផ្លូវការ (បានចុះបញ្ជីជាមួយរដ្ឋាភិបាល) តាមតំបន់ ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

## គ្រោះហានិភ័យ

គ្រោះហានិភ័យសំដៅទៅលើព្រឹត្តិការណ៍កើតមានឡើង ដែលមិនបានគិតទុកជាមុនហើយប៉ះពាល់យ៉ាងខ្លាំងដល់ផលិតកម្ម ឬទីផ្សារ។ នោះអាចអាស្រ័យលើកត្តាធម្មជាតិ ដូចជា គ្រោះរាំងស្ងួត ទឹកជំនន់ សត្វល្អិតចង្រៃបំផ្លាញ ឬជម្ងឺដែលអាចនាំឱ្យដំណាំខូច ប៉ុន្តែពួកគេក៏អាចបង្កើតដោយមនុស្សផងដែរ ដូចជា ការផ្លាស់ប្តូរគោលនយោបាយរដ្ឋាភិបាល ការរឹតបន្តឹងពាណិជ្ជកម្ម ឬជម្លោះដែលរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់។ គ្រោះហានិភ័យទាំងនេះអាចជះឥទ្ធិពលយ៉ាងខ្លាំងដល់វិស័យ កសិកម្ម និងសេដ្ឋកិច្ចកាន់តែធ្ងន់ធ្ងរ។ បញ្ហាទាំងនេះហើយដែលអាចនាំឱ្យមានការកើនឡើងតម្លៃស្បៀង កាត់បន្ថយប្រាក់ចំណូលសម្រាប់កសិករ និងការកើនឡើងនៃភាពក្រីក្រ និងអសន្តិសុខស្បៀងក្នុងចំណោមប្រជាជនដែលងាយរងគ្រោះ។




*ប្រភព: អង្កេតកសិកម្មកម្ពុជា២០២១ ការជ្រើសរើសនៅលើផែនទី NIS-MOP, MAFF ២០២៣*

នៅក្នុងការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ នៅតំបន់បឹងទន្លេសាបមានគ្រួសារកាន់កាប់កសិកម្មច្រើនជាងគេដែលរាយការណ៍ថា បានជួបគ្រោះហានិភ័យស្ទើរតែពេញមួយឆ្នាំប្រមាណ ៣៤៣.០០០ ។ ចំពោះនៅតំបន់ឆ្នេរសមុទ្រ បានរាយការណ៍ថា គ្រួសារកាន់កាប់កសិកម្ម ជួបគ្រោះហានិភ័យមានចំនួនទាបជាងគេប្រមាណ ៤៨.០០០។

រូបទី៥.១៩ ចំនួនកសិដ្ឋានបានរាយការណ៍ថា មានជួបគ្រោះហានិភ័យ តាមតំបន់ ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

យោងទៅតាមគ្រោះហានិភ័យធ្ងន់ធ្ងរនៃគ្រួសារកសិកម្ម ដែលបានជួបប្រទះភាគច្រើនគឺគ្រោះរាំងស្ងួតដែលប៉ះពាល់ដល់គ្រួសារកសិកម្ម មានចំនួនប្រមាណ ២៤៤.០០០ ក្នុងឆ្នាំ២០២១។ គ្រោះហានិភ័យធំទីពីរ គឺទឹកជំនន់ ដែលមានគ្រួសារកសិកម្មចំនួនប្រមាណ ២០៦.០០០ ដែលរាយការណ៍ថា បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើគ្រួសារកសិកម្មក្នុងរយៈពេលយោង។ ទីបីជំងឺកូវីដ-១៩ ត្រូវបានបញ្ជាក់ឡើងថា មានគ្រោះហានិភ័យធ្ងន់ធ្ងរទៅលើគ្រួសារកាន់កាប់កសិកម្ម ជាសរុបមានប្រមាណ ១៣១.០០០។

រូបទី៥.២០ ចំនួនកសិដ្ឋានដែលរាយការណ៍ថាមានជួបគ្រោះហានិភ័យធ្ងន់ធ្ងរ នៅកម្ពុជា ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*




*ប្រភព: អង្កេតកសិកម្មកម្ពុជា ២០២១ ការជ្រើសរើសនៅលើផែនទី NIS-MOP, MAFF ២០២៣*

ក្នុងករណីជាច្រើន គ្រួសារកាន់កាប់កសិកម្មបានឆ្លើយតបថា ពួកគាត់មិនទាន់បានប្រសើរឡើងវិញឲ្យពេញលេញពីគ្រោះហានិភ័យយ៉ាងធ្ងន់ធ្ងរនោះទេ។ ដោយឡែកនៅតំបន់បឹងទន្លេសាប មានគ្រួសារកសិកម្មចំនួនប្រហែល ២៤៧.០០០ បានរាយការណ៍ថា មិនទាន់មានភាពប្រសើរឡើងវិញទេ បើធៀបនឹងចំនួនដែលមានប្រមាណ ៧៣.០០០ ប៉ុណ្ណោះ។ ចំណែកនៅតំបន់វាលទំនាប គឺជាតំបន់តែមួយគត់ដែលគ្រួសារកសិកម្មច្រើនជាងគេ ទទួលបានភាពប្រសើរឡើងវិញទាំងស្រុង បើប្រៀបធៀបទៅនឹងតំបន់ដែលមិនមាន។ លើសពីនេះទៅទៀត មានករណីជាច្រើន គ្រួសារកសិកម្មមិនបានរាយការណ៍ថាអាចទប់ទល់នឹងគ្រោះហានិភ័យធ្ងន់ធ្ងរជាងពេលពីមុន។ ជាថ្មីម្តងទៀត នៅតំបន់បឹងទន្លេសាបបានរាយការណ៍ មានញឹកញាប់បំផុតថា មិនអាចដោះស្រាយនឹងគ្រោះហានិភ័យធ្ងន់ធ្ងរបានទេ។

រូបទី៥.២១ កសិដ្ឋានមានភាពប្រសើរឡើងវិញពីគ្រោះហានិភ័យធ្ងន់ធ្ងរ តាមតំបន់ ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

## ប្រាក់កម្ចី

លទ្ធភាពទទួលបានហិរញ្ញប្បទានមានសារៈសំខាន់ណាស់ សម្រាប់ការកាន់កាប់កសិកម្មខ្នាតតូច នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដោយសារហេតុផលមួយចំនួន រួមទាំងការកែលម្អផលិតភាព ការគ្រប់គ្រងហានិភ័យ លទ្ធភាពទទួលបានទីផ្សារ ការរៀបចំគ្រោះមហន្តរាយ និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច។

រូបទី៥.២២៖ បង្ហាញថា គ្រួសារកាន់កាប់កសិកម្មនៅតំបន់វាលទំនាប ទទួលបានឥណទានច្រើនជាងគេ សម្រាប់ការការពារប្រឆាំងនឹងគ្រោះហានិភ័យពីខាងក្រៅ ជាងតំបន់ផ្សេងទៀត មានប្រមាណ ៣០.០០០។ បន្ទាប់មកគ្រួសារកាន់កាប់កសិកម្មនៅតំបន់បឹងទន្លេសាបបានទទួលបានឥណទានប្រមាណ ២៤.០០០។

រូបទី៥.២២ កសិដ្ឋាន មានលទ្ធភាពទទួលបានឥណទាន (ផ្លូវការ ឬក្រៅផ្លូវការ) សម្រាប់ការការពារប្រឆាំងនឹងគ្រោះហានិភ័យពីខាងក្រៅ តាមតំបន់ ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*

គ្រួសារកាន់កាប់កសិកម្មមានប្រមាណ ២១៨.០០០ នៅក្នុងតំបន់បឹងទន្លេសាប បានរាយការណ៍ថា យ៉ាងហោចណាស់មានមួយកម្ចីឥណទាន បន្ទាប់មក គឺតំបន់វាលទំនាបមានគ្រួសារកសិកម្មប្រមាណ ១៩៤.០០០។ ចំពោះនៅតំបន់ភ្នំ និងខ្ពង់រាបមានប្រមាណ ១១០.០០០ និងនៅតំបន់ឆ្នេរសមុទ្រមាន ប្រមាណ ២៩.០០០។

រូបទី៥.២៣ យ៉ាងហោចណាស់មានសមាជិកគ្រួសារម្នាក់បានខ្ចីប្រាក់ តាមតំបន់ ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១*

គ្រួសារកាន់កាប់កសិកម្មមានប្រហែល ៥៨% បានខ្ចីប្រាក់ដើម្បីប្រើប្រាស់ក្នុងគ្រួសារហើយយ៉ាង ហោចណាស់ផ្នែកខ្លះនៃប្រាក់កម្ចីនោះសម្រាប់គោលបំណងកសិកម្ម។ នៅក្នុងតំបន់បឹងទន្លេសាបគ្រួសារ កាន់កាប់កសិកម្មមានប្រមាណ ១៥១.០០០ បានរាយការណ៍ថា ប្រាក់កម្ចីរបស់ពួកគាត់មានមួយផ្នែកបាន បម្រើឲ្យគោលបំណងកសិកម្មបន្ទាប់មក គឺតំបន់វាលទំនាបមានគ្រួសារកាន់កាប់កសិកម្មប្រមាណ ៩៧.០០០ ចំពោះតំបន់ភ្នំ និងខ្ពង់រាបមានគ្រួសារកាន់កាប់កសិកម្មប្រមាណ ៦១.០០០ និងតំបន់ឆ្នេរសមុទ្រមានគ្រួសារ កាន់កាប់កសិកម្មប្រមាណ ១៣.០០០ បានបម្រើឲ្យក្នុងគោលបំណងវិស័យកសិកម្ម។

### រូបទី៥.២៤ ចំនួនកសិដ្ឋានរាយការណ៍ថាយ៉ាងហោចណាស់ផ្នែកនៃប្រាក់កម្ចីរបស់ពួកគាត់បានប្រើប្រាស់សម្រាប់គោលបំណងកសិកម្ម តាមតំបន់ ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*




*ប្រភព: អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១ ការជ្រើសរើសនៅលើផែនទី NIS-MOP, MAFF ឆ្នាំ២០២៣*

ប្រាក់កម្ចីច្រើនបំផុតត្រូវបានខ្ចីតាមរយៈស្ថាប័នមីក្រូហិរញ្ញវត្ថុ។ ជាសរុបគ្រួសារកាន់កាប់កសិកម្ម មានចំនួនប្រមាណ ៣១៤.០០០ បានរាយការណ៍ថា បានប្រើប្រាស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសម្រាប់ប្រាក់កម្ចីរបស់ពួកគេ ហើយយ៉ាងហោចណាស់មានមួយប្រាក់កម្ចីដែលជាចំនួនខ្ពស់ជាងប្រភពប្រើប្រាស់ធំទីពីរគឺធនាគារមានប្រមាណ ១៦៥.០០០ នៃគ្រួសារកាន់កាប់កសិកម្ម។ ក្រៅពីមីក្រូហិរញ្ញវត្ថុ និងធនាគារ ប្រភពក្រៅផ្លូវការនៃការផ្ដល់ប្រាក់កម្ចី គឺសាច់ញាតិ អ្នកចងការប្រាក់ មិត្តភក្តិ/អ្នកជិតខាង ត្រូវបានរាយការណ៍ផងដែរ។

រូបទី៥.២៥ ប្រភពនៃប្រាក់កម្ចី នៅកម្ពុជា ឆ្នាំ២០២១




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២១*